# ការទទួលខុសត្រូវរបស់មេបញ្ជាការ (command responsibility)

ទម្រង់ទទួលខុសត្រូវប្រភេទនេះ ជាវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ (international customary law) និងមានអត្ថិភាព ក្រោយសង្គ្រាមលោកលើកទី២ ក្នុងការដាក់មេដឹកនាំនយោបាយ ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋប្រព្រឹត្តដោយអ្នកក្រោមបង្គាប់ខ្លួន។

ទម្រង់នេះ ត្រូវបានចែងក្នុងពិធីសារទី១ភ្ជាប់នឹងអនុសញ្ញាហ្សឺណែវឆ្នាំ ១៩៤៩ (AP I) និងលក្ខ ន្តិកៈនៃ ICTY មាត្រា៦(៣)។ ច្បាប់អន្តរជាតិ ដាក់កាតព្វកិច្ចលើមេបញ្ជាការក្នុងការបង្កា ឬបង្ក្រាប បទល្មើសដោយអ្នកក្រោមបង្គាប់។ ដូចនេះ មេបញ្ជាការ មិនមានការទទួលខុសត្រូវដូចគ្នានឹងអ្នកក្រោមបង្គាប់។

ដើម្បីឲ្យមេបញ្ជាការទទួលខុសត្រូវ លក្ខខណ្ឌចំនួនបីត្រូវតែបានបំពេញ៖ ១. ទំនាក់ទំនងរវាងមេ និងកូនចៅ។ ២. មេបញ្ជាការបានដឹង ឬមានហេតុផលថា អ្នកក្រោមបង្គាប់នឹងប្រព្រឹត្ត ឬបានប្រព្រឹត្តបទល្មើស និងទី៣. មេបញ្ជាការ ខកខានចាត់វិធានការសមស្រប និងចាំបាច់ក្នុងការបង្កា ឬដាក់ទោសអ្នកប្រព្រឹត្ត។

សម្រាប់ចំណុចទី១ មេបញ្ជាការ ត្រូវមានការគ្រប់គ្រងមានប្រសិទ្ធភាព (effective control) លើអ្នកក្រោមបង្គាប់ ទោះបីតាមការគ្រប់គ្រង ដោយអំណាចតាមព្រឹត្តន័យ (*de facto*) ក្តី។ ការខកខានក្នុងការបង្ក្រាប គឺអាចវាស់វែងក្នុងកម្រិតអំណាចដែលមេបញ្ជាការមាន។ មេបញ្ជាការ មានអំណាចក្នុងការត្រួតពិនិត្យ។ ការដែលមេបញ្ជាការដាក់ (ordering) បញ្ជា អាចបង្ហាញថាគាត់មានអំណាច។ ការដាក់បញ្ជា នាំឲ្យមានការទទួលខុសត្រូវផ្ទាល់របស់មេបញ្ជាការ (direct liability)។ ក្នុងករណីចូលក្នុងទម្រង់ទាំងពីរ ទម្រង់ទទួលខុសត្រូវផ្ទាល់នឹងត្រូវបានប្រកាន់យក។

មេបញ្ជាការ ត្រូវដឹងជាក់ស្តែង (actual knowledge) ថាអ្នកក្រោមបង្គាប់នឹងប្រព្រឹត្តបទល្មើស ឬមានព័ត៌មាន នាំឲ្យគាត់កត់សំគាល់ ថាមានហានិភ័យនៃបទល្មើស នាំឲ្យមាននូវការស៊ើបអង្កេតបន្ថែម ឲ្យដឹងថាតើបទល្មើសនឹងត្រូវបានប្រព្រឹត្តដែរឬទេ?។ទោះបីជាយ៉ាងនេះក្តី ការពិចារណា នឹងត្រូវធ្វើតាមករណីជាក់ស្តែងនីមួយៗ។

ទម្រង់នេះ ខុសពីទម្រង់ទទួលខុសត្រូវការបញ្ជា ដែលមិនទាមទារនូវទំនាក់ទំនងរវាងមេ និងកូនចៅទេ។ ទម្រង់ខុសត្រូវនេះ ក៏មិនមែនជាទម្រង់ខុសត្រូវតឹងរឹងដែរ (strict liability) ដូចនេះ វាមិនតម្រូវឲ្យបង្ហាញអំពីធាតុផ្សំអត្តនោម័ត (*mens rea*)។

សម្រាប់ការទទួលខុសត្រូវក្នុងទម្រង់នេះ យុត្តិសាស្ត្រ មិនទាមទារនូវចំណងហេតុនិងផល (causation)។

មេបញ្ជាការស៊ីវិល ក៏នឹងទទួលខុសត្រូវក្នុងទម្រង់នេះដែរ ក៏ប៉ុន្តែ ធាតុអត្តនោម័ត អាចមានលក្ខណៈទូលាយជាងនេះ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 270-272)។